ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខៈ ០៤ អយក. សរណន .

# សេចក្តីណែនាំ
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងជ្រើសរើសសិស្សពូកែ ប្រចាំរាជធានី ខេត្ត និងទូទាំងប្រទេស ឆ្នាំ២០១៨

ដើម្បីពង្រឹងគុណភាពអប់រំ និងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយសីលធម៌ និងចំណេះដឹងខ្ពស់ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំពីការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្ត និងទូទាំងប្រទេសនៅគ្រឹះស្ថានមធ្យមសិក្សាតាមខ្លឹមសារដូចខាងក្រោមៈ

**១. ការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្ត**

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវម្ចាស់ការរៀបចំការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្ត ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា ថ្នាក់ទី៩ និងថ្នាក់ទី១២ ដែលប្រព្រឹត្តទៅនៅក្នុងខែមីនា តាមលទ្ធភាព និងគំនិតច្នៃប្រឌិតផ្ទាល់ តាមមុខវិជ្ជា និងតាមកម្រិតថ្នាក់នីមួយៗ រួចបញ្ជូនបេក្ខភាពមកចូលរួមប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស តាមចំនួនកំណត់ក្នុងតារាងបែងចែកជូនភ្ជាប់មកជាមួយនេះ។

ចំពោះសិស្សថ្នាក់ទី៩ និងថ្នាក់ទី១២នៃគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅឯកជនអាចចូលរួមក្នុងការប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្ត តាមរាជធានី ខេត្តរបស់ខ្លួន ជាមួយគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈដែរ។

ដោយឡែកវិទ្យាល័យអនុវត្ត ត្រូវចូលរួមប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្ត ជាមួយគ្រឹះស្ថានមធ្យមសិក្សានានាក្រោមឱវាទមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ។

ប្រធានវិញ្ញាសាប្រឡងជ្រើសរើសសិស្សពូកែប្រចាំរាជធានី ខេត្ត ជាសមត្ថកិច្ចរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តសាមី។

**២. ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស**

**២.១. គោលការណ៍រួមនៃការប្រឡងជ្រើសរើសសិស្សពូកែ**

**ក.ការកំណត់ កម្រិតថ្នាក់ វិញ្ញាសា និងសម័យប្រឡង**

-ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសបានកំណត់យក២កម្រិតថ្នាក់គឺថ្នាក់ទី៩ និងទី១២

-វិញ្ញាសាប្រឡងរួមមានផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា

-សម័យប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស ត្រូវបានកំណត់យក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨

-ប្រធានវិញ្ញាសាប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស រៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា ដោយគិតតាមកម្មវិធីសិក្សាពីថ្នាក់ទី៧ដល់ថ្នាក់ទី៩សម្រាប់ការប្រឡងសិស្សពូកែថ្នាក់ទី៩ និងពី

ថ្នាក់ទី៧ ដល់ថ្នាក់ទី១២សម្រាប់ការប្រឡងសិស្សពូកែថ្នាក់ទី១២។

**ខ.ការរៀបចំពិធី និងមណ្ឌលប្រឡង**

មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម ដែលត្រូវធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសសម្រាប់ឆ្នាំ២០១៨នេះ មានភារកិច្ច៖

-រៀបចំវិទ្យាល័យព្រះសីហនុ សម្រាប់ធ្វើជាមណ្ឌលប្រឡងសិស្សពូកែទូទាំងប្រទេសឆ្នាំ២០១៨ និងរៀបចំទីកន្លែងសម្រាប់ប្រារព្ធពិធីបើក និងពិធីបិទចែកសញ្ញាបត្រនិងរង្វាន់ជ័យលាភីសិស្សពូកែទូទាំងប្រទេសឱ្យហើយស្រេច មុនបើកសម័យប្រឡងសិស្សពូកែ ដោយត្រូវសហការជាមួយនាយកដ្ឋានកិច្ចការប្រឡង (ការិយាល័យប្រឡងជ្រើសរើសសិស្សពូកែថ្នាក់ជាតិ និងអន្តរជាតិ)

-អញ្ជើញអភិបាលរងនៃគណៈអភិបាលខេត្តដើម្បីថ្លែងសុន្ទរកថាស្វាគមន៍ក្នុងពិធីបើក និងអញ្ជើញអភិបាលនៃគណៈអភិបាលខេត្តដើម្បីជាអធិបតីក្នុងពិធីបិទ ចែកសញ្ញាបត្រ និងរង្វាន់ជ័យលាភី និងអញ្ជើញភ្ញៀវចូលរួមជាកិត្តិយសរួមមាន អាជ្ញាធរមូលដ្ឋាន នគរបាល អាវុធហត្ថ និងមន្ទីរពាក់ព័ន្ធមួយចំនួននៅក្នុងខេត្ត

-ត្រូវសហការជាមួយនាយកដ្ឋានកិច្ចការប្រឡង (ការិយាល័យប្រឡងជ្រើសរើសសិស្សពូកែថ្នាក់ជាតិ និងអន្តរជាតិ) ដើម្បីរៀបចំកម្មវិធីដំណើរកំសាន្តរបស់បេក្ខជនតាមរមណីយដ្ឋានកែច្នៃ ធម្មជាតិ វប្បធម៌ ប្រវត្តិសាស្ត្រ ឬទីកន្លែងដែលមានសក្តានុពលផ្សេងទៀតនៅក្នុងខេត្ត ហើយត្រូវធ្វើលិខិតទៅអាជ្ញាធរខេត្តដើម្បីស្នើសុំជួយអន្តរាគមន៍ និងស្នើសុំកម្លាំងសមត្ថកិច្ចនិងអាជ្ញាធរមូលដ្ឋានឱ្យជួយរក្សា សន្តិសុខ និងជួយសម្របសម្រួលការងារផ្សេងៗសំដៅធ្វើឱ្យដំណើរកំសាន្តនេះ ប្រព្រឹត្តទៅប្រកបដោយបរិយាកាសរីករាយ និងសុវត្ថិភាព។

**គ. លក្ខខណ្ឌសម្រាប់បេក្ខជនសិស្សពូកែ**

-បេក្ខជនសិស្សពូកែទាំងអស់ត្រូវស្លៀកពាក់ជាឯកសណ្ឋានសិស្សដោយប្រើអាវពណ៌ស និងខោឬសំពត់ពណ៌ខៀវ។ អាវត្រូវស៊កចូលក្នុងខោឬសំពត់ឱ្យបានត្រឹមត្រូវហើយត្រូវពាក់ប័ណ្ណសម្គាល់ខ្លួននៅពេលចូលមណ្ឌលប្រឡង និងត្រូវចូលរួមពិធីបើក និងបិទការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

-បេក្ខជនសិស្សពូកែម្នាក់ៗអាចជ្រើសរើសមុខវិជ្ជាឯកទេស ដើម្បីធ្វើការប្រឡងបានតែមួយមុខវិជ្ជាប៉ុណ្ណោះក្នុងចំណោម អក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា។ ចំណែកមុខវិជ្ជាវប្បធម៌ទូទៅ ជាមុខវិជ្ជាកាតព្វកិច្ចដែលបេក្ខជនម្នាក់ៗត្រូវបំពេញឱ្យគ្រប់លក្ខខណ្ឌនៃការប្រឡងជ្រើសរើស។ បេក្ខជនម្នាក់ៗត្រូវធ្វើកិច្ចការប្រឡងជាបីពេល គឺ មុខវិជ្ជាឯកទេសដែលខ្លួនបានជ្រើសរើសចំនួនពីរពេល និងមុខវិជ្ជាវប្បធម៌ទូទៅចំនួនមួយពេល

-បេក្ខជនសិស្សពូកែត្រូវបានអនុញ្ញាតឱ្យប្រើម៉ាស៊ីនគិតលេខ ដែលគណៈកម្មការរៀបចំការប្រឡងបានត្រៀមបម្រុងទុកឱ្យខ្ចីប្រើជាស្រេច សម្រាប់បេក្ខជនសិស្សពូកែមុខវិជ្ជារូបវិទ្យា ថ្នាក់ទី៩ និងថ្នាក់ទី១២។

**ឃ.ការគ្រប់គ្រងបេក្ខជនសិស្សពូកែ**

ប្រតិភូប្រចាំរាជធានី ខេត្តនីមួយៗ មានភារកិច្ចដឹកនាំ គ្រប់គ្រងបេក្ខជនសិស្សពូកែរបស់ខ្លួនចាប់តាំងពីពេលចេញដំណើរពីរាជធានី ខេត្តសាមី រហូតដល់ពេលត្រឡប់ទៅដល់រាជធានី ខេត្តរៀងៗខ្លួនវិញ រួមទាំងការស្នាក់នៅ ហូបចុក ជាពិសេសត្រូវចុះជាប់ជាមួយសិស្សនៅពេលធ្វើដំណើរកំសាន្ត ចៀសវាងដាច់ខាតកុំឱ្យ កើតមានបញ្ហាជាយថាហេតុ។

**២.២. ការប្រព្រឹត្តទៅនៃដំណើរការប្រឡង**

*ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៨

- ពេលព្រឹក ៖ ប្រធាន អនុប្រធានមណ្ឌលប្រជុំណែនាំសមាជិកគណៈមេប្រយោគនៅមណ្ឌលប្រឡង វិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម

- ពេលរសៀល ៖ ប្រារព្ធពិធីបើកការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស នៅក្នុង

បរិវេណវិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម វេលាម៉ោង ១៤:០០។

*ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨

-ពេលព្រឹក៖ .ដំណើរការសំណេរ វិញ្ញាសាឯកទេសទី១ មុខវិជ្ជា អក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា ថ្នាក់ទី៩ និងថ្នាក់ទី១២

.គណៈកម្មការកំណែ ៖ ធ្វើអត្រាកំណែតាមមុខវិជ្ជា តាមកម្រិតថ្នាក់

.គណៈកម្មការកណ្តាលកំណែ ៖ ពិនិត្យផ្ទៀងផ្ទាត់ កាត់ក្បាលសន្លឹកកិច្ចការបេក្ខជន និងចុះអក្សរសម្ងាត់លើសន្លឹកកិច្ចការបេក្ខជន

-ពេលរសៀល ៖ កែសន្លឹកកិច្ចការបេក្ខជន។

*ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨

-ពេលព្រឹក ៖ .ដំណើរការសំណេរ វិញ្ញាសា វប្បធម៌ទូទៅ ថ្នាក់ទី៩ និងថ្នាក់ទី១២

.គណៈកម្មការកំណែ ៖ ធ្វើអត្រាកំណែ មុខវិជ្ជាវប្បធម៌ទូទៅ តាមកម្រិតថ្នាក់ និងបន្តកែ សន្លឹកកិច្ចការបេក្ខជនតាមមុខវិជ្ជាឯកទេសរៀងៗខ្លួន

.គណៈកម្មការកណ្តាលកំណែ ៖ ពិនិត្យផ្ទៀងផ្ទាត់ កាត់ក្បាលសន្លឹកកិច្ចការបេក្ខជន និងចុះអក្សរសម្ងាត់ លើសន្លឹកកិច្ចការបេក្ខជន

-ពេលរសៀល ៖ កែសន្លឹកកិច្ចការបេក្ខជន។

*ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨

-ពេលព្រឹក ៖ .ដំណើរការសំណេរ វិញ្ញាសាឯកទេសទី២ មុខវិជ្ជា អក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា ថ្នាក់ទី៩ និងថ្នាក់ទី១២

.គណៈកម្មការកំណែ ៖ ធ្វើអត្រាកំណែតាមមុខវិជ្ជា តាមកម្រិតថ្នាក់ និងកែបន្ត

.គណៈកម្មការកណ្តាលកំណែ ៖ ពិនិត្យផ្ទៀងផ្ទាត់ កាត់ក្បាលសន្លឹកកិច្ចការបេក្ខជន និងចុះអក្សរសម្ងាត់លើសន្លឹកកិច្ចការបេក្ខជន

-ពេលរសៀល ៖ កែសន្លឹកកិច្ចការបេក្ខជន។

*ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨

-បន្តកែសន្លឹកកិច្ចការបេក្ខជន

-នាំបេក្ខជនសិស្សពូកែធ្វើដំណើរកំសាន្តតាមរមណីយដ្ឋានកែច្នៃ ធម្មជាតិ និងវប្បធម៌។

*ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៨

-បន្តកែសន្លឹកកិច្ចការបេក្ខជន

-ស្រង់ បូកពិន្ទុ និងពិនិត្យផ្ទៀងផ្ទាត់ពិន្ទុ

-នាំបេក្ខជនសិស្សពូកែធ្វើដំណើរកំសាន្តតាមរមណីយដ្ឋានកែច្នៃ ធម្មជាតិ និងវប្បធម៌។

*ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៨

-គណៈកម្មការគ្រប់គ្រងទូទៅប្រជុំសម្រេចលទ្ធផលប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

-ក្រោយពេលប្រជុំសម្រេចរួច គណៈកម្មការកណ្តាលកំណែត្រូវបោះពុម្ព៖

·បញ្ជីស្ថិតិលទ្ធផលសិស្សពូកែតាមរាជធានី ខេត្ត

·បញ្ជីចំណាត់ថ្នាក់សិស្សពូកែទូទាំងប្រទេសតាមមុខវិជ្ជានិងកម្រិតថ្នាក់

·ប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេសពីលេខ១ដល់លេខ១០

·សញ្ញាបត្រជ័យលាភីសិស្សពូកែទូទាំងប្រទេសពីលេខ១ដល់លេខ១០

*ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៨

- ពេលព្រឹក ៖ រៀបចំពិធីបិទការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

- ពេលរសៀល ៖ ប្រារព្ធពិធីបិទ ពិធីចែកសញ្ញាបត្រ និងចែករង្វាន់ជ័យលាភីសិស្សពូកែទូទាំងប្រទេសប្រចាំឆ្នាំ ២០១៨ នៅវិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម វេលាម៉ោង ១៤:០០។

### ២.៣. រយៈពេល និងរបបពិន្ទុនៃវិញ្ញាសាប្រឡងនីមួយៗ ថ្នាក់ទី៩ និងថ្នាក់ទី១២

- អក្សរសិល្ប៍ខ្មែរ : ១៨០នាទី ១០០ពិន្ទុ
- គណិតវិទ្យា : ១៨០នាទី ១០០ពិន្ទុ
- រូបវិទ្យា : ១៨០នាទី ១០០ពិន្ទុ
- វប្បធម៌ទូទៅ : ១២០នាទី ១០០ពិន្ទុ

### ២.៤. សំណុំលិខិតបេក្ខជន

ក្រោយពីមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត បានប្រកាសលទ្ធផលរួច សិស្សដែលបានជាប់ជាបេក្ខជនសិស្សពូកែប្រចាំរាជធានី ខេត្ត ត្រូវរៀបចំបំពេញសំណុំលិខិតដើម្បីចូលរួមប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសដូចខាងក្រោម៖

-ពាក្យសុំចុះឈ្មោះប្រឡងសិស្សពូកែទូទាំងប្រទេស *(គំរូជូនភ្ជាប់ទី១)*

-សំបុត្រកំណើតឬសំបុត្របញ្ជាក់កំណើត(ថតចម្លង) សម្រាប់សិស្សថ្នាក់ទី៩ និងថ្នាក់ទី១២

-វិញ្ញាបនបត្របណ្ដោះអាសន្នបឋមភូមិ(ថតចម្លង) សម្រាប់សិស្សថ្នាក់ទី១២

បន្ទាប់ពីបានទទួលសំណុំលិខិតបេក្ខជនរួច ការិយាល័យជំនាញ របស់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ត្រូវ៖

-ប្រើកម្មវិធីគ្រប់គ្រងទិន្នន័យសិស្សពូកែ សម្រាប់បញ្ចូលទិន្នន័យបេក្ខជនសិស្សពូកែ

-ប្រើ Digital Camera សម្រាប់ថតរូបបេក្ខជន ដោយតម្រូវឱ្យបេក្ខជនពាក់អាវស មានបិទស្លាកឈ្មោះ នៅលើអាវផ្នែកខាងលើ ឆ្វេង រួចនាំរូបថតបេក្ខជនចូលទៅក្នុងកម្មវិធីគ្រប់គ្រងទិន្នន័យសិស្សពូកែ

-បោះពុម្ពបញ្ជីសំណើបេក្ខភាពប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស *(គំរូជូនភ្ជាប់ទី២)* ។

★ការិយាល័យជំនាញរបស់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្តត្រូវផ្ញើមកការិយាល័យប្រឡងជ្រើសរើសសិស្សពូកែថ្នាក់ជាតិ និងអន្តរជាតិ នៃនាយកដ្ឋានកិច្ចការប្រឡងនូវសំណុំឯកសារដូចខាងក្រោម៖

១.សំណុំលិខិតបេក្ខជនប្រឡងសិស្សពូកែ

២.បញ្ជីសំណើបេក្ខភាពប្រឡងសិស្សពូកែទូទាំងប្រទេស

៣.Soft Data សិស្សពូកែប្រចាំរាជធានី ខេត្ត

★កាលបរិច្ឆេទផុតកំណត់ទទួលសំណុំឯកសារ៖ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨

★ការិយាល័យប្រឡងជ្រើសរើសសិស្សពូកែថ្នាក់ជាតិនិងអន្តរជាតិ ៖ ស្ថិតនៅក្នុងប្លុកលេខ១៦៩ អគារ នាយកដ្ឋានកិច្ចការប្រឡង ជាន់ទី២ ទូរស័ព្ទលេខ ០២៣ ៧២៦ ៤៦៨ សារអេឡិចត្រូនិច៖ nibsro 2017 @gmail.com , Messenger: nibsro, Telegram: nibsro។

### ២.៥.លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសជ័យលាភីសិស្សពូកែ

១. បេក្ខជនណាមិនគោរពបទប្បញ្ញត្តិនៃការប្រឡង ដូចជា លួចមើលសំណៅផ្សេងៗ ងាកមើលអ្នកជិតខាង ឬសួរគ្នានឹងត្រូវជម្រុះចោល។

២. បេក្ខជនណាដែលមានពិន្ទុវប្បធម៌ទូទៅក្រោមមធ្យមភាគនឹងត្រូវជម្រុះចោល ប៉ុន្តែពិន្ទុវប្បធម៌ទូទៅ មិនត្រូវបានយកទៅបូកនឹងពិន្ទុមុខវិជ្ជាឯកទេសឡើយ។

៣.បេក្ខជនណាដែលមានពិន្ទុវប្បធម៌ទូទៅលើមធ្យមភាគ និងពិន្ទុសរុបមុខវិជ្ជាឯកទេសលើមធ្យមភាគត្រូវបានកំណត់ជាជម្រើសសម្រាប់ប្រជែងជាជ័យលាភីសិស្សពូកែតាមមុខវិជ្ជាឯកទេស តាមកម្រិតថ្នាក់ ដោយជ្រើសយកពីលំដាប់ពិន្ទុខ្ពស់មកទាបជាបន្តបន្ទាប់រហូតដល់ចំណាត់ថ្នាក់លេខ១០។

៤. ក្នុងករណីដែល ការជ្រើសរើសបេក្ខជនសម្រាប់ប្រជែងជាជ័យលាភីសិស្សពូកែ តាមមុខវិជ្ជាឯកទេស តាមកម្រិតថ្នាក់ មិនបានគ្រប់ចំនួនតាមតម្រូវការដូចលក្ខខណ្ឌចែងក្នុងចំណុចទី៣ គណៈគ្រប់គ្រងទូទៅនៃការប្រឡងសិស្សពូកែទូទាំងប្រទេសត្រូវប្រជុំសម្រេចដើម្បីស្រង់យកបេក្ខជនជ័យលាភីបន្ថែមឱ្យគ្រប់ ១០នាក់ ក្នុងមួយមុខវិជ្ជា និងមួយកម្រិតថ្នាក់។

៥. ក្នុងករណី ពិន្ទុសរុបមុខវិជ្ជាឯកទេសស្មើគ្នា ត្រូវអញ្ជើញប្រធាន ឬអនុប្រធានកំណែ មកកែកិច្ចការនោះសាជាថ្មីឡើងវិញតាមបែបកំណែសម្ងាត់។

៦. ក្នុងករណីកែឡើងវិញ ពិន្ទុនៅតែស្មើគ្នាទៀត ត្រូវសម្រេចផ្តល់អាទិភាពជូនបេក្ខជនជានារី។

៧. គ្រប់សន្លឹកកិច្ចការបេក្ខជន ត្រូវកែជារបៀបសម្ងាត់ទាំងអស់។ សន្លឹកកិច្ចការបេក្ខជនម្នាក់ៗ ត្រូវកែដោយអ្នកកែ ២នាក់ផ្សេងគ្នា ដោយដាក់ពិន្ទុសម្ងាត់រៀងៗខ្លួន ហើយពិន្ទុនោះមិនត្រូវសរសេរលើសន្លឹកកិច្ចការបេក្ខជនឡើយ។ ក្រោយពីកែរួច អ្នកកែត្រូវយករបាយពិន្ទុលម្អិតជាសម្ងាត់នោះ មកប្រគល់ជូនប្រធានក្រុមកំណែដើម្បីបញ្ជូនទៅគណៈកម្មការកណ្តាលកំណែ។ របាយពិន្ទុលម្អិតរបស់អ្នកកែទាំង ២នាក់សម្រាប់សន្លឹកកិច្ចការបេក្ខជនម្នាក់នឹងត្រូវយកមកផ្ទៀងផ្ទាត់ឡើងវិញ។

ក្នុងករណីគម្លាតពិន្ទុរវាងអ្នកកែទាំងពីរៈ

-មុខវិជ្ជាអក្សរសិល្ប៍ខ្មែរ និងវប្បធម៌ទូទៅ ក្រោម ឬស្មើ ១០ ពិន្ទុ

-មុខវិជ្ជាគណិតវិទ្យា និងរូបវិទ្យា ក្រោម ឬស្មើ ៥ ពិន្ទុ

ត្រូវសម្រេចយកមធ្យមភាគនៃពិន្ទុរបស់អ្នកទាំងពីរ

ប៉ុន្តែក្នុងករណីគម្លាតពិន្ទុរវាងអ្នកកែទាំងពីរៈ

-មុខវិជ្ជាអក្សរសិល្ប៍ខ្មែរ និងវប្បធម៌ទូទៅ ធំជាង ១០ ពិន្ទុ

-មុខវិជ្ជាគណិតវិទ្យា និងរូបវិទ្យា ធំជាង ៥ ពិន្ទុ

ត្រូវរៀបចំឱ្យកែជាលក្ខណៈសម្ងាត់ឡើងវិញ។

**២.៦. ផលប្រយោជន៍ដែលជ័យលាភីត្រូវទទួលបាន**

បេក្ខជនគ្រប់រូបសុទ្ធតែបានទទួលវិញ្ញាបនបត្រចូលរួមប្រឡងសិស្សពូកែទូទាំងប្រទេស ម្នាក់មួយសន្លឹក។

ចំណែកបេក្ខជនជ័យលាភីសិស្សពូកែទូទាំងប្រទេសម្នាក់ៗត្រូវទទួលបានរង្វាន់ និងការលើកទឹកចិត្តពីរាជរដ្ឋាភិបាលកម្ពុជា តាមចំណាត់ថ្នាក់ដូចខាងក្រោមៈ

-ចំណាត់ថ្នាក់លេខ១ៈប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ សញ្ញាបត្រសិស្សពូកែទូទាំងប្រទេស ១សន្លឹក មេដាយមាស ១គ្រឿង និងថវិកា ៣ ៥០០ ០០០(បីលានប្រាំសែន)រៀល។

-ចំណាត់ថ្នាក់លេខ២ៈប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ សញ្ញាបត្រសិស្សពូកែទូទាំងប្រទេស ១សន្លឹក មេដាយប្រាក់ ១គ្រឿង និងថវិកា ៣ ២០០ ០០០(បីលានពីរសែន)រៀល។

-ចំណាត់ថ្នាក់លេខ៣ៈប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ សញ្ញាបត្រសិស្សពូកែទូទាំងប្រទេស ១សន្លឹក មេដាយសំរិទ្ធ ១គ្រឿង និងថវិកា ២ ៩០០ ០០០(ពីរលានប្រាំបួនសែន)រៀល។

-ចំណាត់ថ្នាក់លេខ៤ៈប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ សញ្ញាបត្រសិស្សពូកែទូទាំងប្រទេស ១សន្លឹក និងថវិកា ២ ៦០០ ០០០(ពីរលានប្រាំមួយសែន)រៀល។

-ចំណាត់ថ្នាក់លេខ៥ៈប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ សញ្ញាបត្រសិស្សពូកែទូទាំងប្រទេស ១សន្លឹក និងថវិកា ២ ៣០០ ០០០(ពីរលានបីសែន)រៀល។

-ចំណាត់ថ្នាក់លេខ៦ៈប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ សញ្ញាបត្រសិស្សពូកែទូទាំងប្រទេស ១សន្លឹក និងថវិកា ២ ០០០ ០០០(ពីរលាន)រៀល។

-ចំណាត់ថ្នាក់លេខ៧ៈប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ សញ្ញាបត្រសិស្សពូកែទូទាំងប្រទេស ១សន្លឹក និងថវិកា ១ ៧០០ ០០០(មួយលានប្រាំពីរសែន)រៀល។

-ចំណាត់ថ្នាក់លេខ៨៖ប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ សញ្ញាបត្រសិស្សពូកែទូទាំងប្រទេស ១សន្លឹក និងថវិកា ១ ៤០០ ០០០(មួយលានបួនសែន)រៀល។

-ចំណាត់ថ្នាក់លេខ៩៖ប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ សញ្ញាបត្រសិស្សពូកែទូទាំងប្រទេស ១សន្លឹក និងថវិកា ១ ១០០ ០០០(មួយលានមួយសែន)រៀល។

-ចំណាត់ថ្នាក់លេខ១០៖ ប្រកាសទទួលស្គាល់សិស្សពូកែទូទាំងប្រទេស ១ច្បាប់ សញ្ញាបត្រសិស្សពូកែទូទាំងប្រទេស ១សន្លឹក និងថវិកា ៨០០ ០០០(ប្រាំបីសែន)រៀល។

សម្គាល់៖បេក្ខជនជ័យលាភីសិស្សពូកែទូទាំងប្រទេស អាចមានប្រាក់រង្វាន់ឬវត្ថុផ្សេងៗបន្ថែមទៀតពីសប្បុរសជន។

**២.៧. ការចំណាយ និងពេលវេលាត្រូវទៅដល់កន្លែងប្រារព្ធពិធី របស់បេក្ខជនសិស្សពូកែ និងគណៈប្រតិភូរាជធានី ខេត្ត**

ប្រតិភូដឹកនាំសិស្សពូកែទូទាំងប្រទេសតាមរាជធានី ខេត្ត ត្រូវ៖

-នាំសិស្សទៅដល់ទីរួមខេត្តកំពង់ចាម នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៨

-ចូលរួមប្រារព្ធពិធីបើកការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស នៅវិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៨ វេលាម៉ោង ១៤:០០ រសៀល

-ការចំណាយក្នុងដំណើរការប្រឡងការរៀបចំពិធីបើកការប្រឡង ពិធីបិទចែកសញ្ញាបត្រ និងចែករង្វាន់ជ័យលាភី សោហ៊ុយធ្វើដំណើរ ស្នាក់នៅ ហូបចុក និងដំណើរកំសាន្តរបស់បេក្ខជនជាបន្ទុករបស់ក្រសួងអប់រំ យុវជន និងកីឡា។

សូមជូនភ្ជាប់មកជាមួយនូវ៖

-តារាងបែងចែកបេក្ខជនសិស្សពូកែ និងប្រតិភូតាមរាជធានី ខេត្ត

-គំរូពាក្យសុំចុះឈ្មោះប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស (គំរូទី១)

-គំរូបញ្ជីសំណើបេក្ខភាពប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស (គំរូទី២)។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាគ្រប់រាជធានី ខេត្ត នឹងផ្សព្វផ្សាយសេចក្តីណែនាំនេះដល់គ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងឯកជន ក្នុងរាជធានី ខេត្ត ព្រមទាំងអនុវត្តសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ... ខែ ... ឆ្នាំរការ នព្វស័ក ពស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

**កន្លែងទទួល ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-ក្រសួងមុខងារសាធារណៈ

"ដើម្បីជ្រាបជាព័ត៌មាន"

-សាលារាជធានី ខេត្ត

-អង្គភាពក្រោមឱវាទទីស្តីការក្រសួងអយក

-មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

"ដើម្បីសហការ អនុវត្ត"

-ឯកសារ-កាលប្បវត្តិ នា.កប្រឡ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

នាយកដ្ឋានកិច្ចការប្រឡង

## តារាងបែងចែកបេក្ខជនសិស្សពូកែ និងប្រតិភូតាមរាជធានី ខេត្ត
## ប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស ឆ្នាំ២០១៨

| លរ | រាជធានី ខេត្ត | បេក្ខជនសិស្សពូកែថ្នាក់ទី៩ | | | បេក្ខជនសិស្សពូកែថ្នាក់ទី១២ | | | សរុបបេក្ខជន | ប្រតិភូ | សរុបរួម |
|---|---|---|---|---|---|---|---|---|---|---|
| | | អក្សរសិល្ប៍ខ្មែរ | គណិតវិទ្យា | រូបវិទ្យា | អក្សរសិល្ប៍ខ្មែរ | គណិតវិទ្យា | រូបវិទ្យា | | | |
| 1 | បន្ទាយមានជ័យ | 4 | 4 | 4 | 3 | 3 | 3 | 21 | 2 | 23 |
| 2 | បាត់ដំបង | 5 | 5 | 5 | 5 | 5 | 5 | 30 | 3 | 33 |
| 3 | កំពង់ចាម | 5 | 5 | 5 | 5 | 5 | 5 | 30 | 3 | 33 |
| 4 | កំពង់ឆ្នាំង | 3 | 3 | 3 | 3 | 3 | 3 | 18 | 2 | 20 |
| 5 | កំពង់ស្ពឺ | 4 | 4 | 4 | 3 | 3 | 3 | 21 | 2 | 23 |
| 6 | កំពង់ធំ | 3 | 3 | 3 | 3 | 3 | 3 | 18 | 2 | 20 |
| 7 | កំពត | 4 | 4 | 4 | 4 | 4 | 4 | 24 | 2 | 26 |
| 8 | កណ្ដាល | 6 | 6 | 6 | 6 | 6 | 6 | 36 | 4 | 40 |
| 9 | កោះកុង | 1 | 1 | 1 | 1 | 1 | 1 | 6 | 1 | 7 |
| 10 | ក្រចេះ | 2 | 2 | 2 | 1 | 1 | 1 | 9 | 1 | 10 |
| 11 | មណ្ឌលគិរី | 1 | 1 | 1 | 1 | 1 | 1 | 6 | 1 | 7 |
| 12 | ភ្នំពេញ | 9 | 9 | 9 | 15 | 15 | 15 | 72 | 7 | 79 |
| 13 | ព្រះវិហារ | 1 | 1 | 1 | 1 | 1 | 1 | 6 | 1 | 7 |
| 14 | ព្រៃវែង | 6 | 6 | 6 | 5 | 5 | 5 | 33 | 3 | 36 |
| 15 | ពោធិ៍សាត់ | 2 | 2 | 2 | 2 | 2 | 2 | 12 | 1 | 13 |
| 16 | រតនគិរី | 1 | 1 | 1 | 1 | 1 | 1 | 6 | 1 | 7 |
| 17 | សៀមរាប | 6 | 6 | 6 | 5 | 5 | 5 | 33 | 3 | 36 |
| 18 | ព្រះសីហនុ | 1 | 1 | 1 | 1 | 1 | 1 | 6 | 1 | 7 |
| 19 | ស្ទឹងត្រែង | 1 | 1 | 1 | 1 | 1 | 1 | 6 | 1 | 7 |
| 20 | ស្វាយរៀង | 3 | 3 | 3 | 3 | 3 | 3 | 18 | 2 | 20 |
| 21 | តាកែវ | 6 | 6 | 6 | 6 | 6 | 6 | 36 | 4 | 40 |
| 22 | កែប | 1 | 1 | 1 | 1 | 1 | 1 | 6 | 1 | 7 |
| 23 | ប៉ៃលិន | 1 | 1 | 1 | 1 | 1 | 1 | 6 | 1 | 7 |
| 24 | ឧត្តរមានជ័យ | 1 | 1 | 1 | 1 | 1 | 1 | 6 | 1 | 7 |
| 25 | ត្បូងឃ្មុំ | 3 | 3 | 3 | 2 | 2 | 2 | 15 | 1 | 16 |
| សរុប | | 80 | 80 | 80 | 80 | 80 | 80 | 480 | 51 | 531 |

ថ្ងៃ សុក្រ ១១ កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ពស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមករា ឆ្នាំ២០១៨

**ប្រធាននាយកដ្ឋានកិច្ចការប្រឡង**

**អ៊ឹង ចៅហុក**

សម្គាល់៖ -អត្រា៖ ចំនួនបេក្ខ.សិស្សពូកែសរុបធៀបនឹងសិស្សសរុបក្នុងខេត្ត
តែមិនលើស៨០នាក់ ក្នុង១មុខវិជ្ជានិង១កម្រិតថ្នាក់
-ប្រតិភូគិតអត្រា 0.1គុណ ចំនួនសិស្សពូកែ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គំរូទី១**

## ពាក្យសុំចុះឈ្មោះប្រឡងសិស្សពូកែទូទាំងប្រទេស
## ផ្នែក អក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា

ខ្ញុំបាទ នាងខ្ញុំឈ្មោះ.......................................... "ជាអក្សរពុម្ពឡាតាំង".........................................
ភេទ.........ជនជាតិ............សញ្ជាតិ............កើតនៅថ្ងៃទី..........ខែ.............ឆ្នាំ..............នៅឃុំ សង្កាត់
................................ខណ្ឌ ស្រុក ................................ រាជធានី ខេត្ត ..........................................
ឪពុកឈ្មោះ ................................................មុខរបរសព្វថ្ងៃ..................................................
ម្ដាយឈ្មោះ ................................................មុខរបរសព្វថ្ងៃ..................................................
មានបងប្អូនបង្កើតចំនួន....................នាក់ ស្រី..............នាក់ ជាកូនទី..........................................
ជាសិស្សថ្នាក់ទី...........អនុវិ./វិទ្យាល័យ ........................................................រាជធានី ខេត្ត.....................
ទីលំនៅបច្ចុប្បន្ន ..........................................................................................................................

**គោរពចូលមក**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

តាមរយៈ៖ លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត.........................................

សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាអនុញ្ញាតចាត់ឱ្យ ចុះឈ្មោះខ្ញុំបាទ នាងខ្ញុំ ក្នុងបញ្ជីបេក្ខភាពប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស សម័យប្រឡង៖២៣ មេសា ២០១៨ នៅមណ្ឌលប្រឡង៖ វិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម ដោយរើសយកមុខវិជ្ជា.........................................ដោយក្ដីអនុគ្រោះ។

សូមជូនភ្ជាប់មកជាមួយនូវ៖

១.សំបុត្រកំណើតឬសំបុត្របញ្ជាក់កំណើត(ថតចម្លង) ............................ ចំនួន ១សន្លឹក
២.វិញ្ញាបនបត្របណ្ដោះអាសន្នមធ្យមសិក្សាបឋមភូមិ (ថតចម្លង) ............................ ចំនួន ១សន្លឹក

សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ នាងខ្ញុំ។

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅ ថ្ងៃទី ខែ ឆ្នាំ២០១៨
ហត្ថលេខានិងឈ្មោះបេក្ខជន

★ពាក្យសុំចុះឈ្មោះប្រឡងនេះ ត្រូវផ្ញើមកនា.កប្រឡ កាវិ.ប្រឡងជ្រើសរើសសិស្សពូកែថ្នាក់ជាតិនិងអន្តរជាតិឱ្យបានមុនថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

(គំរូទី២)

រាជធានី ខេត្ត....................

មន្ទីរអប់រំ យុវជន និងកីឡា

## បញ្ជីសំណើបេក្ខភាពប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

សម័យប្រឡង ៖ .....................................

### ក.ថ្នាក់ទី៩

| លរ | ឈ្មោះ | ភេទ | ថ្ងៃកំណើត | ទី.កំណើត | អាគតដ្ឋាន | ឈ្មោះឪពុក | មុខរបរ | ឈ្មោះម្តាយ | មុខរបរ | បងប្អូន | កូនទី | មុខវិជ្ជា |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |

### ខ.ថ្នាក់ទី១២

| លរ | ឈ្មោះ | ភេទ | ថ្ងៃកំណើត | ទី.កំណើត | អាគតដ្ឋាន | ឈ្មោះឪពុក | មុខរបរ | ឈ្មោះម្តាយ | មុខរបរ | បងប្អូន | កូនទី | មុខវិជ្ជា |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦១

ថ្ងៃទី ខែ ឆ្នាំ២០១៨

ប្រធានមន្ទីរអប់រំ យុវជន និងកីឡា